# ប្រវត្តិ និង ដំណើរនាំទៅដល់ការដួលរលំ នៃរបបកម្ពុជាប្រជាធិបតេយ្យ

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

*ថ្ងៃនេះ កាលពី៥០ឆ្នាំមុន ក្រុងភ្នំពេញត្រូវបានរំដោះ។ មនុស្សជាច្រើន នៅទីក្រុងបាន នាំគ្នាចេញមកក្រៅផ្ទះ ដើម្បីអបអរសាទរទិវាជ័យជម្នះ ១៧ មេសា ១៩៧៥។ ពួកគេគិតថា ការរំដោះក្រុងភ្នំពេញ គឺជាការបិទបញ្ចប់នូវសង្គ្រាមរយៈពេលជាង៥ឆ្នាំរវាងក្រុមទាហានអតីត របបសាធារណរដ្ឋខ្មែររបស់លោក* **លន់ នល់** *ប្រឆាំងនឹងក្រុមយុទ្ធជនតស៊ូខ្មែរក្រហម។ ប៉ុន្តែ គួរឱ្យស្តាយ ថ្ងៃនោះមិនមែនជាថ្ងៃនៃសន្តិភាពឡើយ។ អ្វីៗដែលបានរំពឹងទុក ខុសពីអ្វីដែលបានកើតឡើង។*

*តើខ្មែរក្រហមជាអ្នកណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?*

***ខ្មែរក្រហម*** *គឺជាឈ្មោះដែល សម្តេចព្រះនរោត្តម សីហនុ មានព្រះរាជបន្ទូលសំដៅទៅលើក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ជាផ្លូវការរបស់ ក្រុមនេះគឺ បក្សកុម្មុយនីស្តកម្ពុជា ដែលចូលមកកាន់កាប់ប្រទេសកម្ពុជា នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ។*

## ១.ចលនាខ្មែរក្រហមមុនពេលឡើងកាន់អំណាច

### ១.១-ចលនាកុម្មុយនីស្តដំបូងបំផុត

*ចលនាកុម្មុយនីស្តនៅកម្ពុជា កើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំង ក្នុង អំឡុងទសវត្សរ៍ឆ្នាំ១៩៤០។ នៅខែមេសា ឆ្នាំ១៩៥០ គឺក្នុងអំឡុងពេលនៃ សង្គ្រាមឥណ្ឌូចិន លើកទី១ គណៈប្រតិភូ ចំនួនពីររយនាក់បានមកជួបជុំគ្នានៅខេត្តកំពតហើយបានបង្កើតរណសិរ្ស ឯកភាពឥស្សរៈ (ខ្មែរឥស្សរៈ)ដែលដឹកនាំដោយក្រុមកុម្មុយនីស្ត។ ក្រុមនេះសហការជាមួយ វៀតណាមដើម្បីធ្វើការតស៊ូប្រឆាំងនឹងអាណានិគមបារាំង។ រណសិរ្សនេះដឹកនាំដោយ* **សឺង ង៉ុកមិញ** *ដែលជាអាចារ្យនៅវត្តឧណ្ណាលោម។* **ចាន់**

**សម័យ** មាននាទីជាអនុប្រធានរណសិរ្ស និង **ស៊ីវ ហេង** ជាលេខាធិការ។

**១.២-ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ**

*នៅឆ្នាំ១៩៥១នៅពេលការវាយប្រយុទ្ធប្រឆាំងនឹងបារាំងកាន់តែមានសភាពខ្លាំងក្លាឡើងនៅក្នុងឧបទ្វីបឥណ្ឌូចិន ជនកុម្មុយនីស្តវៀតណាមបានផ្តួចផ្តើមឱ្យមានការបង្កើតឡើងនូវបក្ស ប្រជាជនបដិវត្តន៍ខ្មែរ។ សមាជិករបស់គណៈកម្មាធិការមជ្ឈិមបក្សសម្ងាត់នេះរួមមាន៖*

-**សឺង ង៉ុកមិញ** *កាន់តំណែងកំពូល*

-**ស៊ីវ ហេង** *ទទួលបន្ទុកកិច្ចការកងទ័ព*

-**ទូសា មុត** *ទទួលបន្ទុកអប់រំមនោគមវិជ្ជា*

-**ចាន់ សម័យ** *ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច*

**១.៣-បក្សពលករកម្ពុជា**

*មហាសន្និបាតរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ បានប្រារព្ធធ្វើឡើងជាសម្ងាត់នៅក្នុងស្ថានីយរថភ្លើងនាទីក្រុងភ្នំពេញ ពីថ្ងៃទី២៨ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០។ មហាសន្និបាត នេះត្រូវបានចូលរួមដោយសមាជិកប្រាំពីររូបពីសាខាបក្សនៅទីក្រុង និងដប់បួនរូប ពីសាខាបក្ស នៅជនបទ។ មហាសន្និបាតបានសម្រេចរៀបចំបក្សសាជាថ្មី បង្កើតមាគ៌ានយោបាយថ្មី ប្តូរឈ្មោះ បក្សទៅជា* ***បក្សពលករកម្ពុជា*** *។* **ទូ សាមុត** *បានទទួលតំណែងជាលេខាបក្ស ហើយ* **នួន ជា** *ជាអនុលេខា។ ពេលនោះ* **ប៉ុល ពត** *មានឋានៈលំដាប់ទីបីក្នុងបក្ស ហើយទទួលតំណែងជាអនុលេខាទីពីរ នៅឆ្នាំ១៩៦១។*

*បន្ទាប់ពី* **ទូ សាមុត** *បានបាត់ខ្លួននៅឆ្នាំ១៩៦២ មហាសន្និបាតបក្សជាបន្ទាន់មួយត្រូវបានប្រារព្ធធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៦៣។មហាសន្និបាតបានជ្រើសតាំង***ប៉ុលពត** *ជាលេខាបក្ស។* **នួន ជា** *ដែលមានតំណែងខ្ពស់ជាង* **ប៉ុល ពត** *នៅក្នុងបក្សមិនត្រូវបានជ្រើសរើសទេ ដោយហេតុថា* **នួន ជា** *មានជាប់សាច់ញាតិជាមួយជនក្បត់បក្ស* **ស៊ីវ ហេង**។

**១.៤-បក្សកុម្មុយនីស្តកម្ពុជា**

*នៅខែកញ្ញា ឆ្នាំ១៩៦៦ បន្ទាប់ពីដំណើរបំពេញទស្សនកិច្ចក្រៅប្រទេស* **ប៉ុល ពត** *បានប្តូរឈ្មោះបក្សទៅជា* ***បក្សកុម្មុយនីសកម្ពុជា*** *ដោយហេតុថា* **ប៉ុល ពត** *ចង់បន្ថយឥទ្ធិពលរបស់ វៀតណាម និងរឹតចំណងមិត្តភាពជាមួយចិន។ គណៈកម្មាធិការមជ្ឈិមបក្សនៅពេលនោះរួមមាន៖* **ប៉ុល ពត**, **នួន ជា**, **អៀង សារី**, **វន វ៉េត** *និង* **សុន សេន**។[1]

[1] *ឌី ខាំបូលី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ* ***១៩៧៥-១៩៧៩»*** *មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៧*

នៅខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ **លន់ នល់** និងសហការីរបស់គាត់ដែលនិយមសហរដ្ឋអាម៉េរិកបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ **នរោត្តម សីហនុ** ចេញពីព្រះប្រមុខរដ្ឋ ដោយជោគជ័យ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ កងកម្លាំងវៀតណាម និងខ្មែរក្រហមបានកាន់កាប់ តំបន់ជាច្រើននៅក្នុងប្រទេស។ ប្រជាជនរាប់ម៉ឺននាក់បានបដិសេធមិនគាំទ្ររដ្ឋាភិបាលបាល សាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ **លន់ នល់** ហើយបែរជាចូលរួមជាមួយខ្មែរក្រហមដើម្បីនាំយកសម្តេចព្រះ **នរោត្តម សីហនុ** មកគ្រប់គ្រងអំណាចវិញ។ ក្នុងពេលនោះដែរ សម្តេចព្រះ **នរោត្តម សីហនុ** បាននិរទេសព្រះកាយទៅប្រទេសចិន។ ដោយមានការលើកទឹកចិត្តនិងការជួយជ្រោមជ្រែងពីសំណាក់រដ្ឋាភិបាលចិន រដ្ឋាភិបាលវៀតណាមខាងជើង និង បក្សកុម្មុយនីស្តកម្ពុជា ព្រះអង្គបានបង្កើត **"រណសិរ្សរួបរួមជាតិកម្ពុជា"** និងរដ្ឋាភិបាលនិរទេស មួយដែលមានឈ្មោះថា **"រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា"**។ សមាជិកបក្សកុម្មុយនីស្តកម្ពុជាក៏ជា សមាជិករបស់រដ្ឋាភិបាលរួមជាតិកម្ពុជាដែរ។

## ២.ការឡើងកាន់អំណាចរបស់ខ្មែរក្រហម

### ២.១-ការចូលកាន់កាប់ទីក្រុងភ្នំពេញ

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ចប់នូវការជ្រៀតជ្រែកពីសំណាក់បរទេស ការទម្លាក់គ្រាប់បែក និងការប្រឈមអាវុធដាក់គ្នានៃសង្គ្រាមស៊ីវិលខ្មែររយៈពេល៥ឆ្នាំនៅកម្ពុជា។ ប៉ុន្តែ នៅថ្ងៃដដែលនេះ ទីក្រុងភ្នំពេញបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់កងកម្លាំងកុម្មុយនីស្ត ទាំងស្រុង។

កងកម្លាំងឧទ្ទាមដែលប្រកបដោយឯកសណ្ឋានពណ៌ខ្មៅ និងពណ៌អាចម៍សេះ បានធ្វើដំណើរចូលទីក្រុងពីគ្រប់ទិសទី។ ប្រជាជនទីក្រុងទាំងអស់ បាននាំគ្នាចេញមកឈរត្រៀបត្រាតាមដងផ្លូវ ហើយស្រែកអបអរសាទរ និងគ្រវីទង់ក្រណាត់ស។ ទោះជាយ៉ាងនេះក្តី ក៏មានមនុស្សជាច្រើននាក់បានសម្ងំលាក់ខ្លួននៅក្នុងផ្ទះដោយព្រួយបារម្ភថាខ្លួនអាចត្រូវចាប់ ឬបាញ់សម្លាប់ ព្រោះភ្លាមៗនោះ ខ្មែរក្រហមបានប្រកាសតាមវិទ្យុជាតិថាខ្លួនមិនមែនមកដើម្បីចរចាជាមួយ នរណាទាំងអស់ ហើយនឹងធ្វើការប្រហារជីវិតមន្ត្រីជាន់ខ្ពស់និងមេបញ្ជាការទ័ពរដ្ឋាភិបាលចាស់។

ភ្លាមៗបន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ ខ្មែរក្រហមបានប្រហារជីវិតមេដឹកនាំជាន់ខ្ពស់បីរូប មន្ត្រីរាជការ និងនាយទាហានរាប់រយនាក់របស់រាជរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ មេដឹកនាំជាន់ខ្ពស់ទាំងបីរូបនេះ រួមមាននាយករដ្ឋមន្ត្រី **ឡុង បូរ៉េត** ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរិមតៈ** និង **លន់ ណុន** (ប្អូនប្រុសរបស់លោកសេនាប្រមុខ **លន់ នល់**)។

### ២.២-ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន

*ប្រជាជននៅតាមទីក្រុង និងទីប្រជុំជនភាគច្រើនជឿជាក់ថាខ្លួននឹងរស់នៅប្រកបដោយ សុខសន្តិភាព ក្រោមការគ្រប់គ្រងរបស់មេដឹកនាំថ្មីរបស់ខ្លួន ហើយថាប្រជាជនគ្រប់រូបនឹងពួត ដៃគ្នាធ្វើការដើម្បីបង្រួបបង្រួមជាតិ។ ផ្ទុយទៅវិញ ពីរឬបីម៉ោងបន្ទាប់ពីកាន់កាប់ទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមបាញ់រះទៅលើអាកាសជាសញ្ញាបង្ខំឱ្យប្រជាជនចាកចេញពីទីក្រុង។*

*ខ្មែរក្រហមបានបង្ខំអ្នករស់នៅទីក្រុងភ្នំពេញប្រហែលពីរលាននាក់ ដែលក្នុងនោះរួម បញ្ចូលទាំងអ្នកភៀសខ្លួនក្នុងអំឡុងពេលសង្គ្រាមជាងមួយលាននាក់ផងឱ្យទៅជនបទ។ ក្នុង រយៈពេលមួយសប្តាហ៍ ប្រជាជនក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀតដែលធ្លាប់គ្រប់គ្រង ដោយរបបសាធារណរដ្ឋខ្មែរ ត្រូវបានបណ្តេញចេញទៅធ្វើការងារកសិកម្មនៅតំបន់ជនបទ។*

## ៣-ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

### ៣.១-អង្គការ

*ទោះបីជាខ្មែរក្រហម បានធ្វើចម្បាំងប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ* **លន់ នល់** *អស់រយៈពេលប្រាំឆ្នាំក៏ដោយ ក៏ចលនានិងមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ។ បក្សកុម្មុយនីស្តកម្ពុជាបានរក្សាការសម្ងាត់នេះ ស្ទើរតែពេញរយៈពេលដែលខ្លួនគ្រប់គ្រងប្រទេសកម្ពុជា។ អង្គការបដិវត្តន៍ត្រូវបានបង្កើតឡើងដោយសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ អ្នកទាំងនេះត្រូវបានដឹកនាំដោយសម្ងាត់ពីសំណាក់* **ប៉ុល ពត**។

*នៅខែកញ្ញា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ត រួមមាន៖* **ប៉ុល ពត**, **នួន ជា**, **សោ ភឹម**, **អៀង សារី**, **សុន សេន**, **តាម៉ុក** និង **វន វ៉េត**។ *នៅឆ្នាំ១៩៧៧ សមាជិកបីនាក់ទៀត (***ញឹម រស់**, **ខៀវ សំផន** និង **កែ ពក**) *ត្រូវបានបញ្ចូលទៅក្នុងគណៈកម្មាធិការនេះ។* **ប៉ុល ពត**, **អៀង សារី**, **សុន សេន** និង **ខៀវ សំផន** *បានទទួលការអប់រំនៅប្រទេសបារាំង ចំណែក* **នួន ជា** *ធ្លាប់បានសិក្សារៀនសូត្រនៅប្រទេសថៃ និងវៀតណាម។ សមាជិកផ្សេងៗទៀតនៃគណៈកម្មាធិការមជ្ឈិមមានចំណេះដឹងបន្តិចបន្តួចប៉ុណ្ណោះ។*

**•ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៧៦-១៩៧៨**

| | |
|---|---|
| ១-**ប៉ុល ពត** | លេខាបក្ស |
| ២-**នួន ជា** | អនុលេខាបក្ស |
| ៣-**សោ ភឹម** សមាជិក | |
| ៤-**អៀង សារី** | សមាជិក |
| ៥-**សុន សេន** | សមាជិក |
| ៦-**តាម៉ុក** | សមាជិក |
| ៧-**វន វ៉េន** | សមាជិក |

៨-**កែ ពក** សមាជិក
៩-**ខៀវ សំផន** សមាជិក
១០-**ញឹម រស់** សមាជិក

*បញ្ជាក់៖* **វន វ៉េត** និង **ញឹម រស់** *ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៨។* **សោ ភឹម** *ធ្វើអត្តឃាតនៅឆ្នាំ១៩៧៨។* **សុន សេន** *ត្រូវបានសម្លាប់នៅឆ្នាំ១៩៩៧។* **ម៉ុល ពត** *បានស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៩៨។* **កែ ពក** *បានស្លាប់ដោយសារជំងឺនៅឆ្នាំ២០០២។* **តាម៉ុក** *ស្លាប់ដោយសារជំងឺនៅឆ្នាំ២០០៦ ។* **អៀង សារី** *ស្លាប់ដោយសារជំងឺនៅឆ្នាំ ២០១៣។* **នួន ជា** *ស្លាប់ដោយសារជំងឺនៅឆ្នាំ ២០១៩។*

## ៣.២-រចនាសម្ព័ន្ធចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ

*បក្សកុម្មុយនីស្តកម្ពុជា គឺជាអង្គការតែមួយគត់ដែលមានអំណាច នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រសួងដែលមានសកម្មភាពការងារច្រើនដែលត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ រួមមាន ក្រសួងការបរទេសដឹកនាំដោយ* **អៀង សារី** *ក្រសួងការពារជាតិដឹកនាំដោយ* **សុន សេន** *ក្រសួងឧស្សាហកម្មដឹកនាំដោយ* **ចេង អន** *និងក្រសួងសេដ្ឋកិច្ចដឹកនាំដោយ* **វន វ៉េត**។ *គណៈកម្មាធិការតែមួយគត់ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងអនុម័តគោលនយោបាយរដ្ឋាភិបាល និងលក្ខន្តិកៈផ្សេងៗ គឺជាគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែលមាន* **ម៉ុល ពត** *ជាលេខា និង* **នួន ជា** *ជាអនុលេខា។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមិនដែលយកចិត្តទុកដាក់គោរពរដ្ឋធម្មនុញ្ញ និងបទបញ្ញត្តិនានាដែលមេដឹកនាំ ទាំងនេះជាអ្នកអនុម័តបង្កើតឡើងដោយខ្លួនឯងម្តងណាទេ។ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមបក្ស ក៏មានតំណែងនៅក្នុងរដ្ឋាភិបាលដែរ។*

## ៤.ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ

*នៅឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកកម្ពុជាប្រជាធិបតេយ្យទៅជា៦ភូមិភាគ ដែលរួមមាន៣២តំបន់។ ភូមិភាគនីមួយៗគឺយកខេត្តពីរ ឬច្រើនមកបញ្ចូលគ្នា ឬកាត់ចេញពីខេត្តនេះ ឬខេត្តនោះខ្លះមកបញ្ចូលគ្នា។ ភូមិភាគ និងតំបន់ទាំងអស់សុទ្ធតែត្រូវបានដាក់កំណត់សម្គាល់ជាលេខ។ ភូមិភាគនីមួយៗចែកចេញជាច្រើនតំបន់ ហើយតំបន់នីមួយៗចែកចេញជាស្រុក ឃុំ និងសហករណ៍។*

***-ភូមិភាគបូព៌ា*** *(ភូមិភាគ២០៣) ដឹកនាំដោយ* **សោ ភឹម** *ដែលធ្វើអត្តឃាតនៅខែឧសភា ឆ្នាំ១៩៧៨។*

***-ភូមិភាគនិរតី*** *(ភូមិភាគ៤០៥) ដឹកនាំដោយ* **ឈិត ជឿន** *ហៅ* **តាម៉ុក**។

*-**ភូមិភាគឧត្តរ*** (ភូមិភាគ ៣០៣) ដឹកនាំដោយ **ក្រុយ ធ្លូន** ហៅ **ធុច** ពីឆ្នាំ ១៩៧០ ទៅដើម ឆ្នាំ១៩៧៦ ។ បន្ទាប់ពី **ក្រុយ ធ្លូន** ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែងនៅឆ្នាំ ១៩៧៦ **កែ ពក** ត្រូវបានចាត់តាំងជាលេខាភូមិភាគ។

*-**ភូមិភាគពាយ័ព្យ*** (ភូមិភាគ ៥៦០) ដឹកនាំដោយ **ញឹម រស់**។

*-**ភូមិភាគបស្ចិម*** (ភូមិភាគ ៤០១) ដឹកនាំ **ជូ ជេត**។

*-**ភូមិភាគឦសាន*** (ភូមិភាគ ១០៨) ដឹកនាំដោយ **ណៃ សារ៉ាន់** ហៅ **យ៉ា** (ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៦)

## ៥.គម្រោងផែនការបួនឆ្នាំ (១៩៧៧-១៩៨០)

ខ្មែរក្រហមបានធ្វើការបោសសំអាតទីក្រុង និងទីប្រជុំជននានា ដើម្បីលុបបំបាត់ចោលការរស់នៅទីក្រុង និងកសាងកម្ពុជាមួយថ្មីដោយពឹងផ្អែកលើការពង្រីកផលិតកម្មស្រូវ។ ដើមឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានប្រញាប់ប្រញាល់រៀបរៀងផែនការបួនឆ្នាំលើកទីមួយ (១៩៧៧-១៩៨០) ដែលតម្រូវឱ្យធ្វើការប្រមូលផ្តុំនូវរាល់សម្បត្តិឯកជនទាំងអស់ និងដាក់ការដាំដុះស្រូវជាអាទិភាពចម្បងរបស់ជាតិ។ បន្ទាប់ពីបញ្ហាសន្តិសុខជាតិ សមូហភាវូបនីយកម្ម គឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ។

ប្រជាជនកម្ពុជាមិនដែលជួបប្រទះការប្រមូលផ្តុំបែបនេះទេតាំងពីមុនមក។ ប៉ុន្តែក្នុងឆ្នាំ ១៩៧៦ ប្រជាជនគ្រប់រូបត្រូវបានតម្រូវឱ្យប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់របស់ខ្លួន (រួមទាំងសម្ភារៈផ្ទះបាយផង)ដើម្បីប្រើប្រាស់រួមៗ ជាផ្នែកមួយនៃដំណើរការនេះដែរ គ្រួសារខ្មែរទាំងអស់ត្រូវបានបំបែកចេញពីគ្នា ហើយប្រជាជនគ្រប់រូបត្រូវបានចាត់តាំងឱ្យទៅធ្វើការតាមក្រុមរៀងៗខ្លួន។ ប្តីប្រពន្ធត្រូវបានបំបែកឱ្យរស់នៅផ្សេងពីគ្នា ហើយកូនៗត្រូវបានបំបែកចេញពីឪពុកម្តាយ។ ផែនការបួនឆ្នាំមានគោលដៅសម្រេចឱ្យបានផលិតផលស្រូវបីតោនក្នុងមួយហិកតាជាមធ្យម។ នេះជាកិច្ចការមួយដែលមិនអាចធ្វើទៅកើតដោយហេតុថាប្រជាជនកម្ពុជាមិនដែលត្រូវបានបង្ខំឱ្យធ្វើការដាំដុះស្រូវយ៉ាងសម្បើមក្នុងទូទាំងប្រទេសបែបនេះទេតាំងពីបុរាណកាលមក។ ជាងនេះទៅទៀត ប្រទេសជាតិត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមហើយមានការខ្វះខាតឧបករណ៍ សត្វពាហនៈ និងកម្លាំងពលកម្មមាំមួនយ៉ាងច្រើន។

ផែនការបួនឆ្នាំមានរួមបញ្ចូលទាំងគម្រោងដាំបន្លែបង្ការ ហើយសង្ឃឹមថានឹងអាចទាញប្រាក់ចំណូលពីអនុផលព្រៃឈើការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យសង្ឃឹមថានឹងធ្វើឱ្យកម្ពុជាមានឯករាជ្យពេញបរិបូរណ៍ទាំងវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យនយោបាយ

និងមានបំណងប្រែក្លាយកម្ពុជាពីប្រទេសកសិកម្មអន់ថយ ឱ្យទៅកសិកម្មសម័យទំនើបមួយ។

## ៦.ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### ៦.១-ការបង្កើតសហករណ៍

ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០-១៩៧៥ ប្រជាជនភាគច្រើនដែលរស់នៅតាមតំបន់រំដោះរបស់ខ្មែរក្រហមត្រូវបានរៀបចំឱ្យទៅជា "ក្រុមប្រវាស់ដៃ" ដែលមានសមាជិកពី១០ ទៅ៣០គ្រួសារក្នុងមួយក្រុម។ ទោះជាយ៉ាងនេះក្តី ចាប់ពីឆ្នាំ១៩៧៣ និងជាពិសេសបន្ទាប់ពីជ័យជម្នះ ឆ្នាំ១៩៧៥ ក្រុមប្រវាស់ដៃត្រូវបានរៀបចំឱ្យទៅជា "សហករណ៍កម្រិតទាប" ដែលមានសមាជិក បីបួនរយនាក់ ឬក៏ក្នុងភូមិមួយ ទាំងមូល។ រហូតឆ្នាំ១៩៧៧ សហករណ៍កម្រិតទាបត្រូវបានរៀបចំឡើងវិញឱ្យទៅជា "សហករណ៍កម្រិតខ្ពស់" ដែលរួមមានមួយពាន់គ្រួសារក្នុងសហករណ៍នីមួយៗ ឬក៏ឃុំមួយទាំងមូល។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតសហករណ៍ទាំងនេះឡើង ដែលជាផ្នែកមួយនៃដំណើររបស់ខ្លួនទៅរកការលុបបំបាត់ចោលកម្មសិទ្ធិឯកជននិងរបបមូលធននិយម និងដើម្បីពង្រឹងវណ្ណៈកម្មករនិងកសិករ។ ចំពោះខ្មែរក្រហម សហករណ៍មានន័យថា ប្រជាជនរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នាហូបជាមួយគ្នា និងចែករំលែកការកំសាន្តជាសមូហភាព។ គោលការណ៍នេះធ្វើឱ្យមានការដាក់កំហិតយ៉ាងតឹងរ៉ឹងទៅលើការរស់នៅរបស់បុគ្គល។ គ្រួសារខ្មែរធ្លាប់រស់នៅហូបចុកជួបជុំគ្នារាប់ពាន់ឆ្នាំមកហើយ ដូច្នេះការបង្ខំប្រជាជនឱ្យហូបរួមគ្នានៅក្នុងសហករណ៍ ជាពិសេសនៅពេលមានការខ្វះខាតអាហារយ៉ាងខ្លាំងបែបនេះ គឺជាទង្វើមួយឃោរឃៅខ្លាំងណាស់។ ជាងនេះទៅទៀត ប្រជាជនត្រូវប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួន ដែលជាមធ្យោបាយផលិតកម្មសំខាន់ៗដាក់ជាសម្បត្តិរួមរបស់សហករណ៍ទាំងអស់ ដែលមានដូចជា ឧបករណ៍ប្រើប្រាស់ គោក្របី នង្គ័ល រនាស់ គ្រាប់ពូជ និងដីស្រែជាដើម។

សហករណ៍ត្រូវបានរៀបចំឡើងដើម្បីធ្វើយ៉ាងណាអាចឱ្យខ្លួនឧបត្ថម្ភខ្លួនដោយខ្លួនឯងបាន។ មេដឹកនាំខ្មែរក្រហមបានពណ៌នាសហករណ៍ ថាជា "កម្លាំងធំធេងខ្លាំងក្លា" ក្នុងការកសាងប្រទេស និងជា "កំផែងថែបយ៉ាងរឹងមាំបំផុត" សម្រាប់ការពារកម្ពុជាប្រជាធិបតេយ្យទប់ទល់នឹងសត្រូវ។

នៅក្នុងសហករណ៍នីមួយៗគេប្រើរគាំងជាសញ្ញា ហើយក្នុងមួយថ្ងៃយើងបានស្តាប់រគាំងប្រាំដង។

រគាំងគោះខ្លាំងពេល**ទៀបភ្លឺ**
ម្នាក់ៗត្រូវព្រួតក្រោករហ័ស
សំឡេងរគាំងចាំឱ្យច្បាស់
ធ្វើការឱ្យណាស់គ្មានទេហត់។

*រគាំង**ថ្ងៃត្រង់**ព្ររឿយ*
*សម្រាកដល់ហើយម៉ោងកំណត់*
*ស្រូតហូបបបរប្រយ័ត្នអត់*
*ជីវិតល្វីងចត់ចត់ល្វីងក្រៃ។*
*រគាំងគោះហៅពេល**ម៉ោងមួយ***
*បានក្រមាជួយទប់ទល់ថ្ងៃ*
*តែចិត្តធំក្ដៅក្ដៅស្មើរក្សៃ*
*ក្ដៅចិត្តជាងថ្ងៃក្ដៅក្រៃណា។*
*រគាំងពេលល្ងាច**ថ្ងៃហៀបលិច***
*កម្លាំងសល់តិចយោងអាត្មា*
*ហូបបបរខ្សោះខ្សោយកាយា*
*ហូបជួយសង្ខារខ្វាចរលត់។*
*រគាំងគោះទៀត**ក្បាលរាត្រី***
*ហៅទិទៀនស្ដីរៀនហាត់ពត់*
*ពង្រឹងការងាររលត់ដំលត់*
*លត់ឱ្យអត់ធ្មត់មុនចូលដេក។*[2]

## ៦.២-វណ្ណៈសង្គមថ្មីពីរ

*ទោះបីជាខ្មែរក្រហមបានអះអាថាខ្លួនកំពុងតែកសាងប្រទេសមួយប្រកបដោយសមភាពនិងលុបបំបាត់ចោលវណ្ណៈសង្គមយ៉ាងណាក៏ដោយប៉ុន្តែជាតុពិតខ្មែរក្រហមបានបង្កើតឡើង នូវវណ្ណៈថ្មីពីរនៅក្នុងប្រទេស គឺ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី" ។*

*ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ គឺអ្នកទាំងឡាយណាដែលរស់នៅតាមតំបន់ជនបទ គ្រប់គ្រងដោយបក្សកុម្មុយនីស្ដកម្ពុជាមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ ខ្មែរក្រហមបានបែងចែកអ្នកទាំងនេះជាប្រជាជនពេញសិទ្ធិ ឬប្រជាជនត្រៀម។ ប្រជាជនពេញសិទ្ធិ គឺជាអ្នកទាំងឡាយណាដែលមិនមានបងប្អូនធ្លាប់ធ្វើការក្នុងរបបសាធារណៈខ្មែរ ហើយជាសមាជិកគ្រួសារកសិករក្រ ឬកសិករកណ្ដាលថ្នាក់ក្រោម (កសិករនិងកម្មករ)។ ប្រជាជនប្រភេទនេះត្រូវបានអនុញ្ញាតឱ្យទៅបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោត ទោះបីតែការបោះឆ្នោតមានតែម្ដងគត់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យក៏ដោយ។ (ការបោះឆ្នោតនេះមិនអនុលោមតាមបទដ្ឋានអន្តរជាតិ ហើយឈ្មោះសមាជិកសភាតំណាងប្រជាជនក៏មិនត្រូវបានប្រកាសឱ្យប្រជាជនដឹងដែរ)។ ប្រជាជនមូលដ្ឋានអាចក្លាយជាប្រធានសហករណ៍ និងប្រធានកងផ្សេងៗ។ ប្រជាជនត្រៀម គឺអ្នកទាំងឡាយដែលមានបងប្អូនធ្លាប់ធ្វើការជារបបសាធារណៈរដ្ឋខ្មែរ។ ប្រជាជនទាំងនេះនឹងត្រូវបានត្រាប្រណី ដរាបណាប្រជាជនទាំងអស់នោះខិតខំធ្វើការងារដោយខ្ជាប់ខ្ជួន។*

*ប្រជាជនថ្មី ឬប្រជាជន ១៧មេសា គឺជាអ្នកដែលត្រូវជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានានៅខែមេសា ឆ្នាំ១៩៧៥។ ទោះបីជាយ៉ាងនេះក្ដី មួយចំនួនធំនៃអ្នកទាំង*

[2] *ម៉ៅ អាយុទ្ធ «**សំឡេងសាដៀវ**» រង្វាន់ជ័យលាភីតែងនិពន្ធក្របខ័ណ្ឌអាស៊ាន ឆ្នាំ២០០១*

នេះគឺជាអ្នកមកពីជនបទ ហើយបានរត់ទៅទីក្រុងដើម្បីគេចពីសង្គ្រាម។ ប្រជាជនថ្មីត្រូវបានគេចាត់ទុកថាជាមនុស្សដែលមិនអាចជឿទុកចិត្តបាន ហើយទទួលការស្អប់ខ្ពើមនិងសង្ស័យពីសំណាក់អង្គការ។ ប្រជាជនទាំងនេះត្រូវបានអង្គការចាត់ទុកថាជា "ជនបញ្ញើក្អែក" ហើយគ្មានសិទ្ធិអ្វីទាំងអស់ ដូចដែលពាក្យស្លោកខ្មែរក្រហមមួយបានអះអាងថា "ពួក១៧មេសាជាជនបញ្ញើក្អែក"។ ពួកវាជាអ្នកចាញ់សង្គ្រាមនិងជាឈ្លើយសឹក"។ ពាក្យស្លោកមួយទៀតដែលអ្នករស់រានមានជីវិតភាគច្រើនចងចាំនោះគឺ "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ ប្រជាជនថ្មីទទួលរងការធ្វើទុក្ខបុកម្នេញខ្លាំងជាងប្រជាជនចាស់។ ប៉ុន្តែ ទំហំនៃអំពើឃោរឃៅមានកម្រិតខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀត។ ឧទាហរណ៍ ប្រជាជននៅខេត្តស្វាយរៀង និងខេត្តព្រៃវែង ក្នុងភូមិភាគបូព៌ាបានទទួលការគាំពារពីបដិវត្តន៍ប្រសើរជាងអ្នកដែលត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងនៃភូមិភាគពាយ័ព្យ។

### ៦.៣-ពិធីរៀបមង្គលការ

មង្គលការក្នុងរបបកម្ពុជាប្រជាធិបតេយ្យខុសគ្នាទាំងស្រុងពីមង្គលការតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ កូនកម្លោះក្រមុំទាំងអស់ត្រូវរៀបចំក្នុងពិធីរួមតែមួយ ដែលមានចំនួនពី ៣ ទៅ១០គូក្នុងពិធីតូច ហើយពិធីធំមានពី៣០ទៅ៥០គូ ឬរហូតទៅដល់១០០គូក្នុងពិធីនីមួយៗ។ បុរសនារីភាគច្រើនមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសគូស្រករបស់ខ្លួនទេ។ គូនីមួយៗ បានត្រូវចាត់តាំងឡើងដោយអង្គការ ដែលអះអាងថាជាឪពុកម្តាយរបស់មនុស្សគ្រប់រូប។ អ្នកខ្លះមិនទាំងស្គាល់ឈ្មោះ និងមុខមាត់អនាគតគូស្រករបស់ខ្លួនផងទេរហូតដល់ពេលប្រារព្ធពិធីតែម្តង។ បងប្អូនសាច់ញាតិមិនអនុញ្ញាតឱ្យចូលរួមក្នុងពិធីមង្គលការ ឬចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយឡើយ។ សម្លៀកបំពាក់ប្រពៃណី ពិធីរាំវែក ចម្រៀងប្រពៃណី និងពិធីតាមបែបសាសនាត្រូវបានហាមឃាត់។

នារីមួយចំនួនត្រូវបានបង្ខំឱ្យរៀបការជាមួយយុទ្ធជនពិការ ដែលរងរបួសក្នុងពេលសង្គ្រាម ហើយត្រូវដាច់ដៃ ឬដាច់ជើងម្ខាង។ នារីដែលជំទាស់មិនទទួលយកបុរសពិការទាំងនេះអាចត្រូវចាប់ឃុំឃាំង ទទួលរងទណ្ឌកម្មជាទម្ងន់ ឬត្រូវបញ្ជូនឱ្យទៅធ្វើការនៅតំបន់ដាច់ស្រយាលឆ្ងាយៗពីផ្ទះ។ នារីខ្លះដែលជួបប្រទះហេតុការណ៍បង្ខំបែបនេះបានធ្វើអត្តឃាត។

### ៦.៤-ការរំលោភលើសិទ្ធិនិងពលកម្មរបស់កុមារ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមានសាលារៀនជាផ្លូវការទេ។ កុមារត្រូវបានបញ្ជូនឱ្យទៅរៀននៅក្រោមដើមឈើ ឬនៅក្រោមផ្ទះប្រជាជន។ គ្រូភាគច្រើនជាកសិករក្រដែលអាចអាន និងសរសេរតែបន្តិចបន្តួច

ប៉ុណ្ណោះ។ ទោះជាការអប់រំនៅតាមតំបន់មួយចំនួនមានការរីកចម្រើនក្នុងឆ្នាំ ១៩៧៨ក៏ដោយ (កុមារទទួលបានការសិក្សាថ្នាក់បឋមពី២ ទៅ៣ម៉ោងក្នុងមួយថ្ងៃ) ក៏នៅតែមិនទាន់មានសាលារៀនដែលមានដំណើរការពេញលេញដែរ។ ខ្មែរក្រហមនិយាយថា "អង្គការគ្មានសញ្ញាបត្រទេ មានតែសញ្ញាឃើញ បើចង់បានបាក់អង ឬ បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ" ហើយ "ការរៀនអក្សរ រៀនលេខមិនសំខាន់ទេ ការសំខាន់គឺការងារ និងចលនាបដិវត្តន៍"។

នៅពេលដែលកុមារត្រូវបានបង្ហាត់បង្រៀនឱ្យចេះអាន និងសរសេរអក្សរបន្តិចបន្តួចនោះភាគច្រើននៃការសិក្សាគឺផ្តោតទៅលើការអប់រំនយោបាយ។ ក្មេងៗជាច្រើនត្រូវបានយកចេញពីផ្ទះឱ្យទៅចូលវគ្គហ្វឹកហ្វឺនមនោគមវិជ្ជា ដើម្បីអាចបម្រើក្នុងជួរកងទ័ព កងការពារ ឬនិរសារ។

កូនក្មេងក៏ត្រូវបានចាត់តាំងឱ្យធ្វើការងារដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការងាររបស់កុមារគឺ ដើររើសអាចម៍គោ កាត់ទន្រ្ទានខែត្រ ប្រមូលលាមកមនុស្សដើម្បីធ្វើជី និងបញ្ជូនអាវុធទៅសមរភូមិ ដែលនៅទីនោះជួនកាលកុមារត្រូវទទួលរងរបួស ឬក៏ត្រូវគ្រាប់កាំភ្លើងស្លាប់ក៏មាន។ ជាងនេះទៅទៀត កុមារាកុមារីទាំងនេះ ត្រូវបំបែកចេញពីឪពុកម្តាយ ហើយមិនដែលស្គាល់ភាពកក់ក្តៅពីគ្រួសារឡើយ។

កុមារទាំងឡាយត្រូវបានបង្ហាត់បង្រៀនថា "អង្គការជាឪពុកម្តាយរបស់កុមារាកុមារី និងយុវជនយុវនារី។ បើម៉ែឪវាយកូន មានន័យថាមើលងាយអង្គការ ដូច្នេះអង្គការនឹងមិនប្រណីឡើយ"។ កម្មាភិបាលខ្មែរក្រហមបានឱ្យកុមារស៊ើបការណ៍ពីឪពុកម្តាយរបស់ខ្លួនហើយជួនកាលកុមារទាំងនោះហ៊ានទាំងសម្លាប់ឪពុកម្តាយបង្កើតរបស់ខ្លួនទៀតផង ប្រសិនបើទទួលបានបញ្ជាពីអង្គការ។ មួយរយៈកាលកន្លងផុតទៅ កុមារទាំងឡាយជឿតែទៅលើអ្វីដែលអង្គការបានប្រាប់ និងគោរពតាមតែបញ្ជារបស់អង្គការប៉ុណ្ណោះ។

ក្នុងអំឡុងពេលសង្រ្គាមជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧-១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់ ឬរងរបួសជាទម្ងន់។ ខ្មែរក្រហមបានបញ្ជូនកុមារឱ្យទៅសមរភូមិមុខ ដែលនៅទីនោះកុមាររាប់ពាន់នាក់បានត្រូវរបួស និងស្លាប់បាត់បង់ជីវិត។

បទចម្រៀងសម្រាប់កុមារ

«**យើងខ្ញុំកុមារ ស្រឡាញ់អង្គការឥតមានព្រំដែន**»

១-យើងខ្ញុំកុមារ ស្រឡាញ់អង្គការ
ឥតមានព្រំដែន ដោយសារអង្គការ
យើងខ្ញុំរស់រាន ជីវិតថ្កើងថ្កាន
រីករាយអស្ចារ្យ។
២-មុនបដិវត្តន៍ កុមារក្រខ្សត់ រងទុក្ខវេទនា
រស់ដូចសត្វជាតុ កំព្រាខ្វោចផ្សា
អាក្បត់មោហោ គ្មានទឹកនាដល់។

៣-ស្បែកដណ្តប់ឆ្អឹង    ស្គាំងស្គមកំព្រឹង
ហៅសែនកន្ទល់ យប់ដេកនឹងដី
ថ្ងៃឡើងខ្វាយខ្វល់ កាយកាកសំណល់
ដើរសុំទានគេ។
៤-ឥឡូវយើងខ្ញុំ អង្គការឧត្តម ឧបត្ថម្ភគ្រប់គ្នា
បំប៉នសុខភាព កម្លាំងខ្លាំងក្លា  ឱ្យរស់នៅជា
សមូហភាព។
៥-មានស្លៀកមានពាក់ លែងរងាញាក់
លែងរស់ឋោកទាប រស្មីបដិវត្តន៍ រស្មី ស្មើភាព
សិទ្ធិសេរីភាព  ចាំងចែងឆ្អិនឆ្អៅ។
៦-អុះឱអង្គការ  យើងខ្ញុំស្នេហា
យ៉ាងសែនជ្រាលជ្រៅ យើងខ្ញុំប្ដេជ្ញា
ដើរតាមផ្លូវត្រូវ ផ្លូវក្រហមឆ្អៅ
អង្គការបវរ។
៧-ខិតខំរៀនសូត្រ ឱ្យចេះចាំស្ទាត់
លេខនិងអក្សរ ពលកម្មជំនាញ
សតិអារម្មណ៍ល្អ ដើម្បីបន្ត
វេនបដិវត្តន៍។[3]

## ៦.៥-ការបង្ខំឱ្យធ្វើការជាទម្ងន់

ប្រជាជនគ្រប់រូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចាត់តាំងឱ្យធ្វើការទាំងអស់។ កុមារត្រូវបានដាក់ឱ្យធ្វើការងារស្រាលៗ ចំណែកមនុស្សចាស់ៗមាននាទីមើលថែទាំកុមារតូចៗ និងសត្វពាហនៈ និងត្បាញកញ្ច្រែងល្អី។ មនុស្សដែលមានអាយុពី១៤ឆ្នាំ(កុមារវ័យជំទង់) ត្រូវការងារធ្ងន់ៗ និងលំបាក។ កុមារជំទង់ៗទាំងនេះត្រូវជីកប្រឡាយ ឬអាងស្តុកទឹក លើកទំនប់ កាប់ឈើធ្វើផ្ទះ រានដី ធ្វើស្រែចម្ការ និងដាំស្រូវ។ បុរសស្ត្រីប្រហែលពីរ-បីពាន់នាក់ដែលបក្សទុកចិត្តត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅរោងចក្រឯទីក្រុងភ្នំពេញ។

ប្រជាជនស្ទើរគ្រប់រូបធ្វើការច្រើនជាងដប់ពីរម៉ោងក្នុងមួយថ្ងៃ និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដោយមិនមានពេលសម្រាក និងទទួលទានអាហារតិចតួចបំផុត។ ជួនកាលប្រជាជនធ្វើការតាំងពីព្រលឹមស្រាងៗរហូតដល់ពាក់កណ្តាលយប់បើសិនជាខែភ្លឺ។ ថ្ងៃណាដែលមិនមានលោកខែ គេអុចភ្លើងបំភ្លឺវាលស្រែដើម្បីធ្វើការបន្ត។ ប្រសិនបើប្រជាជនតវ៉ានឹងការងារដែលកំណត់ឱ្យដោយប្រធានសហករណ៍ ប្រជាជនទាំងនេះនឹងត្រូវចោទប្រកាន់ថាជាខ្មាំងរបស់បដិវត្តន៍ ហើយនឹងត្រូវបញ្ជូនទៅអប់រំ។ អ្នកដែលប្រព្រឹត្តកំហុសដដែលៗ ឬកំហុសធ្ងន់ធ្ងរនឹងត្រូវយកទៅសម្លាប់ចោល។

## ៦.៦-វិសុទ្ធកម្មនិងការសម្លាប់រង្គាល

ខ្មែរក្រហមតែងតែស្រាវជ្រាវរកចាប់ខ្មាំង ហើយជឿជាក់ថាខ្មាំងមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងទូទាំងប្រទេស។ ជន

[3] ណុន សុខា «**ឥទ្ធិពលមនោគមវិជ្ជានៃអក្សរសិល្ប៍កម្ពុជាប្រជាធិបតេយ្យ**» និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ ឆ្នាំ២០១៥។

សង្ស័យជាច្រើនត្រូវបានចោទប្រកាន់ទាំង ច្រឡំថាជាភ្នាក់ងារសម្ងាត់របស់សហរដ្ឋ អាម៉េរិក(សេ-អ៊ី-អា) ភ្នាក់ងារសម្ងាត់របស់ សូវៀត (កា-ហ្សេ-បេ) ឬក៏ភ្នាក់ងារសម្ងាត់ របស់វៀតណាម។

ការប៉ះទង្គិចជាមួយវៀតណាមក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ១៩៧៨ បាននាំទៅដល់ការធ្វើ វិសុទ្ធកម្ម ដ៏ធំធេងមួយ។ នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពី **ប៉ុល ពត** វិលត្រឡប់ពីប្រទេសចិន វិញ កងទ័ពវៀតណាម បានវាយចូលភាគ បូព៌ានៃប្រទេសកម្ពុជា។ បី-បួនខែក្រោយមក ទ័ពវៀតណាមបានដកថយទៅវិញ ដោយ កៀរយកប្រជាជនស៊ីវិលខ្មែររាប់រយនាក់ទៅ ជាមួយផង។ នៅពេលនេះ ខ្មែរក្រហមបាន ចោទប្រជាជន និងកម្មាភិបាលភូមិភាគបូព៌ា ថា បានចូលដៃចូលជើងជាមួយវៀតណាម។ ហេតុការណ៍នេះបាននាំទៅដល់ការចាប់ខ្លួន និងសម្លាប់ចោលមនុស្សជាច្រើននាក់ រួមទាំង អ្នកដែលស្មោះត្រង់នឹងខ្មែរក្រហម និងដៃគូ នយោបាយដើងចាស់របស់ខ្លួនដ៏យូរលង់ ដូចជា **សោ ភឹម** ទៀតផង។

វិសុទ្ធកម្មដ៏សាហាវយង់ឃ្នងបំផុតនៅ ក្នុងភូមិភាគនេះកើតឡើងនៅឆ្នាំ១៩៧៨ បន្ទាប់ពីកងពលមួយចំនួននៃភូមិភាគនេះ បានធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យ។ ចាប់តាំងពីខែមិថុនា ដល់ខែកញ្ញា នៅពេលដែលការប៉ះទង្គិច ជាមួយវៀតណាមកំពុងតែបន្ត តំបន់ ភាគច្រើននៅក្នុងភូមិភាគនេះបានក្លាយទៅ ជាសមរភូមិរវាងកងទ័ពរដ្ឋាភិបាលកម្ពុជាប្រ ជាធិបតេយ្យ និងកងទ័ពបះបោរ។ មនុស្ស ប្រហែលមួយសែននាក់ក្នុងភូមិភាគបូព៌ាបាន ស្លាប់ក្នុងសមរភូមិ និងដោយសារការសម្លាប់ រង្គាល។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានបញ្ជូនកងទ័ពពីភូមិភាគនិរតីទៅបង្ក្រាប ក្រុមបះបោរ។ ប្រជាជនរាប់ពាន់នាក់បានរត់ ទៅព្រំដែនវៀតណាម គេចពីការសម្លាប់ រង្គាលដែលផ្ទុះឡើង បន្ទាប់ពីការមកដល់នៃ កងទ័ពទាំងនេះ។

វិសិទ្ធកម្មក៏បានកើតឡើងផងដែរនៅ ភូមិឧត្តរក្នុងឆ្នាំ១៩៧៧។ វិសុទ្ធកម្មនេះផ្តោត ទៅលើបញ្ញវន្ត និងអ្នកដែលមានជាប់ ពាក់ព័ន្ធនឹង **កុយ ធួន** ដែលធ្វើជាលេខា ភូមិភាគឧត្តររហូតដើមឆ្នាំ១៩៧៦។ អំឡុង ពេលធ្វើវិសុទ្ធកម្មនេះ អង្គការបានចាប់ខ្លួន រដ្ឋមន្ត្រីក្រសួងព័ត៌មាន **ហ៊ូ នឹម**, **ទិវ អុល** (គ្រូរបស់ **កុយ ធួន**) និងមិត្តភក្តិជាច្រើននាក់ ទៀតដែលរួមមាន **តោគ ឆាយ** និង **ឌឿន** ជាដើម។ មានគម្រោងធ្វើរដ្ឋប្រហារបី-បួន លើក និងមានការបះបោរជាច្រើនដង (ជា ពិសេសការបះបោររបស់ជនជាតិចាម) ក្នុង របបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែ ផែនការ ទាំងនេះសុទ្ធតែបរាជ័យ ហើយបានធ្វើឱ្យការ ស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងមានសភាពកាន់ តែខ្លាំងក្លាឡើង ដែលនាំទៅដល់ការធ្វើវិសុទ្ធ កម្មនៅទូទាំងប្រទេស។

## ៧.ប្រព័ន្ធសន្តិសុខ

### ៧.១-មន្ទីរសន្តិសុខ

ទោះបីវិសុទ្ធកម្មនៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ គឺជាព្រឹត្តិការណ៍ព្រៃផ្សៃបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ប្រជាជនរាប់សែននាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន ហើយក្នុងករណីជាច្រើន ត្រូវបានសម្លាប់ចោលនៅតាមតំបន់ផ្សេងៗទៀតក្នុងទូទាំងប្រទេស។ ប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហមដែលរួមានជិតពីររយគុកត្រូវបានបង្កើតឡើងស្ទើរគ្រប់ទីកន្លែងទាំងអស់លើផ្ទៃប្រទេស។ ខ្មែរក្រហមបានហៅគុកទាំងនេះថា "មន្ទីរសន្តិសុខ" ជាជាងការប្រើពាក្យ"គុក"។

មន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរៀបចំឡើងជាប្រាំថ្នាក់។ មន្ទីរសន្តិសុខទាំងនេះត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង កន្លែងសួរចម្លើយ និងកន្លែងសម្លាប់។ អ្នកទោសដែលជាប់ឃុំក្នុងគុកបីថ្នាក់ដំបូង (ថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ) ភាគច្រើនជាអតីតទាហាន និងមន្ត្រីរដ្ឋការស៊ីវិលរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ហើយអ្នកទោសផ្សេងទៀតគឺជាប្រជាជនសាមញ្ញ ដែលត្រូវបានចោទប្រកាន់ពីបទលួចរបស់របរ ឬចំណីអាហារ រត់ចោលកន្លែង ឬនិយាយអាក្រក់ពីអង្គការ។ មន្ទីរសន្តិសុខថ្នាក់ភូមិភាគធ្វើការឃុំឃាំងអ្នកទោសរាប់ពាន់អ្នក។ មន្ទីរសន្តិសុខទាំងនេះប្រើប្រាស់សម្រាប់ឃុំឃាំងយុទ្ធជនខ្មែរក្រហមនិងក្រុមគ្រួសារ ហើយនិងអ្នកដែលជាប់ចោទពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងភូមិភាគ។ មន្ទីរសន្តិសុខថ្នាក់ខ្ពស់បំផុតគឺជាមន្ទីរសន្តិសុខមជ្ឈិមនៅភ្នំពេញដែលមានឈ្មោះសម្ងាត់ថា "មន្ទីរស-២១"។ អ្នកទោសក្នុងមន្ទីរស-២១ស្ទើរតែទាំងអស់គឺកម្មាភិបាល និងកងទ័ពខ្មែរក្រហមដែលជាប់ចោទពីបទក្បត់បដិវត្តន៍។

នៅមន្ទីរសន្តិសុខថ្នាក់ក្រោម ការធ្វើទណ្ឌកម្មមិនសូវជាធ្ងន់ធ្ងរប៉ុន្មានទេ ដោយសារជាទូទៅ អ្នកទោសត្រូវបានបញ្ជូនពីមន្ទីរសន្តិសុខទៅជំរំពលកម្ម ដែលនៅទីនោះអ្នកទោសត្រូវបានចាត់តាំងឱ្យសាងសង់ផ្ទះ ដាំបន្លែបង្ការ និងចំអិនម្ហូបអាហារ។ អ្នកទោសជាច្រើនដែលជាប់ឃុំក្នុងមន្ទីរសន្តិសុខទាំងនេះត្រូវបានដោះលែងវិញនៅមុនឆ្នាំ១៩៧៦។ ប៉ុន្តែចាប់តាំងពីឆ្នាំនោះមក នៅថ្នាក់តំបន់និងថ្នាក់ស្រុក ស្ទើរតែគ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងឡើយ ហើយស្ទើរតែគ្មានអ្នកទោសណាម្នាក់អាចរួចរស់ជីវិតពីមន្ទីរស-២១ដែរ។

### ៧.២-ខ្មាំងរបស់អង្គការ

ខ្មែរក្រហមចង់ឱ្យបដិវត្តន៍របស់ខ្លួន និងប្រជាជនទាំងអស់មានភាពស្អាតស្អំ។ ប្រជាជនទាំងអស់ ត្រូវតែស្អាតស្អំ ទាំងសតិអារម្មណ៍ និងប្រវត្តិរូប។ កសិករក្រីក្រត្រូវខ្មែរក្រហមចាត់ទុកថាជាអ្នកបដិវត្តន៍ស្អាតស្អំបំផុត។ ខ្មែរក្រហមមិនទុកចិត្តអ្នកផ្សេងក្រៅពីកសិករក្រទាំងនេះឡើយ។ ប្រជាជនដែល

បានប្រព្រឹត្តកំហុសតូចតាច ដូចជាការរអ៊ូរទាំអំពីការធ្វើការលំបាក ឬក៏ការលួចម្ហូបអាហារ ត្រូវបានចាត់ទុកថាជាខ្មាំងរបស់រដ្ឋ និងជាញឹកញយបានក្លាយទៅជាមុខសញ្ញាដែលត្រូវបានយកទៅសម្លាប់ចោល។ មេដឹកនាំខ្មែរក្រហមបានបែងចែកសត្រូវរបស់ខ្លួនជាពីរប្រភេទគឺ "សត្រូវខាងក្នុង" និង "សត្រូវខាងក្រៅ" ។

សត្រូវខាងក្នុង គឺជា "ប្រជាជនថ្មី" ឬ "ប្រជាជន១៧មេសា" និងអ្នកដែលធ្លាប់ធ្វើការក្នុងរបបចាស់។ អ្នកទាំងនេះត្រូវខ្មែរក្រហមចាត់បញ្ចូលជាពួកមូលធននិយម និងពួកសក្តិភូមិនិយម។ ជំពូកប្រជាជនទាំងនេះ ក៏រួមបញ្ចូលទាំងអ្នកដែលមិនមានដើមកំណើរជាជនជាតិខ្មែរផងដែរ។ សត្រូវខាងក្នុងទាំងនេះធ្វើឱ្យមជ្ឈិមបក្សមានការខ្វល់ខ្វាយជាងអ្វីៗទាំងអស់។

សត្រូវខាងក្រៅ សំដៅទៅលើសហរដ្ឋអាម៉េរិក និងសម្ព័ន្ធមិត្ត ដូចជាប្រទេសថៃ និងប្រទេសសង្គមនិយមមួយចំនួន ជាពិសេសប្រទេសវៀតណាម និងអតីតសហភាពសូវៀត។ ខ្មែរក្រហមយល់ថាប្រទេសទាំងអស់នេះមានគោលបំណងឈ្លានពាន និងប៉ុនប៉ងចង់យកកម្ពុជាដាក់ក្រោមអាណានិគម។ ខ្មែរក្រហមបានចោទប្រកាន់មនុស្សជាច្រើនរួមទាំងកម្មាភិបាល និងកងទ័ពរបស់ខ្លួនថាបានបម្រើឱ្យមនោគមវិជ្ជារបស់ប្រទេសទាំងនេះ។ ខ្មែរក្រហមបានហៅអ្នកទាំងនេះថាជា "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង"។ អ្នកទាំងនោះរួមមានអ្នកដែលមកពីប្រទេសដែលប្រឆាំងនឹងរបបសង្គមនិយម ដឹកនាំដោយសហរដ្ឋអាម៉េរិក និងប្រទេសសេរីនិយម ឬប្រទេសអនុត្តរភាពនិយម ដូចជាអតីតសហភាពសូវៀត វៀតណាម និងសម្ព័ន្ធមិត្តដទៃទៀត។

## ៧.៣-ការចាប់ខ្លួននិងការឃុំឃាំង

នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងបានក្លាយជាកិច្ចការចម្បងរបស់ខ្មែរក្រហម។ ខ្មែរក្រហមបានធ្វើឱ្យអ្នកភូមិស៊ើបការណ៍ពីគ្នាទៅវិញទៅមក ដោយប្រើពាក្យស្លោកមួយថា "ត្រូវចេះតាមដានគ្នាទៅវិញទៅមកត្រូវរាយការណ៍ជូនអង្គការ"។ មធ្យោបាយផ្សេងៗទៀតដែលខ្មែរក្រហមបានប្រើក្នុងការស្វែងរកចាប់ខ្លួនខ្មាំងបង្កប់ រួមមានការឈ្លបយកការណ៍ របាយការណ៍ពីអ្នកយកការណ៍ ការធ្វើប្រវត្តិរូបផ្ទាល់ខ្លួនញឹកញាប់ និងចម្លើយសារភាព។

នៅពេលដែលខ្មាំងត្រូវបានរកឃើញឈ្មោះរបស់របស់អ្នកទាំងនេះនឹងត្រូវរាយការណ៍ទៅគណៈកម្មធិការឃុំ ឬគណៈកម្មាធិការស្រុក ហើយបន្ទាប់មកអ្នកទាំងនេះនឹងត្រូវចាប់ខ្លួន។ អង្គការកម្រចាប់ខ្លួនអ្នកណាម្នាក់ជាសាធារណៈណាស់។ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងសហករណ៍ត្រូវបានសង្ស័យ កម្មាភិបាលសហករណ៍នឹងប្រាប់អ្នកនោះថា "អង្គការអញ្ជើញទៅរៀនសូត្រ"។

ក្រោមលេសអញ្ជើញនេះ ជនរងគ្រោះជាច្រើនត្រូវបានចាប់បញ្ជូនទៅមន្ទីរឃុំឃាំង និងសម្លាប់ចោល ជាញឹកញាប់ ដោយមិនការកាត់សេចក្តី ឬស្រាវជ្រាវឱ្យបានហ្មត់ចត់ថាតើអ្នកទាំងនោះពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋបែបនោះមែន ឬក៏មិនមែនទេ។ ខ្មែរក្រហមនិយាយថា "សុខចិត្តចាប់ខុស ១០ មិនឱ្យលែងខុស ១"។

### ៧.៤-ការសួរចម្លើយ និងការធ្វើទារុណកម្ម

អ្នកដែលជាប់ចោទពីបទល្មើសស្រាលៗ ឬជាប់ឃុំក្នុងមន្ទីរសន្តិសុខថ្នាក់ទាបជាទូទៅច្រើនទទួលរងនូវការទទួលទានអាហារមិនគ្រាប់គ្រាន់ ជំងឺគ្មានការព្យាបាល និងប្រព្រឹត្តអំពើយង់ឃ្នងផ្សេងៗទៀត។ ទោះបីជាមនុស្សជាច្រើនស្លាប់ក្នុងស្ថានភាពបែបនេះក៏ដោយ ក៏មានមនុស្សមួយចំនួនទៀតបានរួចផុតពីទារុណកម្ម និងការសម្លាប់ដែរ។ប៉ុន្តែនៅមន្ទីរសន្តិសុខថ្នាក់ខ្ពស់របស់ខ្មែរក្រហមដូចជាមន្ទីរស-២១ ការសួរចម្លើយ និងការធ្វើទារុណកម្ម គឺជាសកម្មភាពជម្មតាប្រចាំថ្ងៃ។[4]

### ៧.៥-ការសម្លាប់

ក្រោមរបបកម្ពុជាប្រជាធិតេយ្យ ប្រជាជនប្រហែលប្រាំសែននាក់ត្រូវបានសម្លាប់ក្រោមបទប្រព្រឹត្តអំពើឧក្រិដ្ឋប្រឆាំងបដិវត្តន៍ និងរដ្ឋ។ ប្រជាជនថ្មីរាប់ពាន់នាក់ដែលមិនមានបទពិសោធន៍ ឬជំនាញក្នុងការធ្វើស្រែចម្ការបានបាត់ខ្លួន។ ប្រជាជនត្រូវបាននាំយកទៅព្រៃជ្រៅ ឬទៅវាលឆ្ងាយពីភូមិស្រុកដើម្បីសម្លាប់ បន្ទាប់ពីប្រជាជនទាំងនោះបានប្រព្រឹត្តនូវអំពើដែលខ្មែរក្រហមបានចាត់ទុកថាជាកំហុស ឬបានបញ្ចេញកាយវិការខឹងសម្បានឹងថ្នាក់ដឹកនាំរបស់ខ្លួន។ ជនរងគ្រោះខ្លះត្រូវបានកប់ទាំងរស់ ហើយស្លាប់ដោយថប់ដង្ហើម។

មនុស្សស្ទើរគ្រប់រូបដែលត្រូវបានរកឃើញថា ជាអ្នកដែលធ្លាប់មានការរៀនសូត្រជ្រៅជ្រះ ត្រូវបានយកទៅសម្លាប់ចោល។ ជាទូទៅគ្មានអ្នកណាម្នាក់ហ៊ានពាក់វ៉ែនតា ឬនិយាយភាសាបរទេសឡើយ ព្រោះវាជាសញ្ញាបង្ហាញថាជននោះជាអ្នកចេះដឹង។ ជាពិសេស អ្នកដែលមកពីទីក្រុងត្រូវតែលាក់ប្រវត្តិរូប និងចំណេះដឹងរបស់ខ្លួនហើយធ្វើពុតជាមនុស្សល្ងង់ខ្លៅ។

ការសម្លាប់ត្រូវបានធ្វើឡើងច្រើនបែបច្រើនសណ្ឋាន។ អ្នកខ្លះត្រូវខ្មែរក្រហមចោទថាក្បត់បដិវត្តន៍ ឬជាខ្មាំងត្រូវបានបញ្ជូនទៅមន្ទីរសួរចម្លើយ។ បន្ទាប់ពីនៅទីនោះបានមួយរយៈពេលពីរ-បីខែ អ្នកទោសនឹងត្រូវយកទៅវាលពិឃាតដែលអ្នកទាំងនោះត្រូវបង្ខំឱ្យលុតជង្គង់នៅមាត់រណ្តៅ។ បន្ទាប់មក អ្នកទោសទាំងនេះនឹងត្រូវសម្លាប់ដោយវាយចំផ្នែកខាង

[4] ឌី ខាំបូលី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» ដ.ឯ.ម.

ក្រោយនៃក្បាលជាមួយនឹងប៉ែល ចបកាប់ ឬដំបង។ ជួនកាល មនុស្សរហូតទៅដល់មួយរយនាក់ត្រូវបាញ់សម្លាប់ក្នុងពេលតែមួយ ហើយកប់ក្នុងរណ្ដៅតែមួយ។ អ្នកខ្លះទៀតត្រូវធ្វើឱ្យថប់ដង្ហើមស្លាប់ដោយយកថង់ផ្លាស្ទិកច្រកក្បាល។ នៅជនបទដែលមានអណ្ដូងជាច្រើននៅក្នុងព្រៃ អ្នកទោសត្រូវបានដឹកតាមឡានធំទៅដល់មាត់អណ្ដូង ហើយបន្ទាប់មកកងឈ្លបក៏រុញ ឬវាយទម្លាក់ទៅក្នុងនោះតែម្ដង។

ពេលខ្លះ សមាជិកគ្រួសារទាំងអស់ត្រូវបានយកទៅសម្លាប់ចោល ដោយសារតែកំហុសដែលបានប្រព្រឹត្តដោយសារសមាជិកម្នាក់។ ខ្មែរក្រហមបានស្វែងរកចាប់ខ្លួនសមាជិកទាំងអស់យកទៅសម្លាប់ក្រោមទ្រឹស្ដីថា "ជីកស្មៅត្រូវជីកទាំងឫស"។

«កងបដិវត្តន៍វិលសកម្ម
មិត្តត្រូវចំណាំត្រូវត្រង់ស្មោះ
លួកដៃលូកជើងដាច់ទាំងអស់
បដិវត្តន៍លោតផ្លោះកុំរាំងរា»[5]

## ៨.ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

### ៨.១-មូលហេតុបីនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ

*-សភាពទុរ្គតទ្រោមរបស់ប្រជាជន៖*

ផែនការបួនឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យបញ្ជាក់ថា កម្ពុជានឹងផលិតឱ្យបានបីតោនក្នុងមួយហិកតារៀងរាល់ឆ្នាំ។ តួលេខនេះមានចំនួនច្រើនលើសទិន្នផលមុនសម័យបដិវត្តន៍។ នៅពេលទិន្នផលស្រូវមិនគ្រប់ផែនការកំណត់ កម្មាភិបាលនៅទូទាំងប្រទេសបានធ្វើរបាយការណ៍ក្លែងក្លាយ។ បន្ទាប់មកកម្មាភិបាលទាំងនេះនឹងបញ្ជូនស្រូវយ៉ាងច្រើនទៅតាមចំនួនផែនការកំណត់ ដោយទុកឱ្យប្រជាជនទទួលរងការអត់ឃ្លាន។

ដោយសារតែប្រតិបត្តិការទូទាំងប្រទេសជាការសម្ងាត់នោះ ធ្វើឱ្យផែនការក្នុងការប្រមូលទិន្នផលស្រូវឱ្យបានបីតោនក្នុងមួយហិកតាមិនអាចអនុវត្តបាន។ តំបន់ទាំងអស់ទូទាំងប្រទេសមិនត្រូវបានអនុញ្ញាតឱ្យចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ឬត្រួតពិនិត្យមើលថាតើមានបញ្ហាអ្វីខ្លះកំពុងកើតមានឡើងទេ។ មជ្ឈិមបក្សកម្រចុះមើលស្ថានភាពរស់នៅរបស់ប្រជាជន ឬរៀបចំផែនការឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់ខ្លួនអនុវត្តណាស់។ មេដឹកនាំថ្នាក់លើហាក់បីដូចជាជឿទាំងស្រុងនូវអ្វីដែលថ្នាក់ក្រោមបានរាយការណ៍ ចំណែកថ្នាក់ក្រោមមិនហ៊ានរាយការណ៍ព័ត៌មានមិនល្អណាមួយទៅថ្នាក់លើឡើយ។ មន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាជឿជាក់ថា បក្សមិនដែលប្រព្រឹត្តកំហុស និងមិនដែលសម្រេចចិត្តខុសទាល់តែសោះ។ រាល់បញ្ហាដែលកើតមានឡើង

[5] ម៉ៅ អាយុទ្ធ «**សំឡេងសាដៀវ**» ជ.ឯ.ម.

ត្រូវបានមេដឹកនាំទាំងនោះចោទប្រកាន់ថាជាកំហុសរបស់ជនបរទេស ឬជនក្បត់។ ដោយសារតែលក្ខខណ្ឌ រស់នៅកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ ប្រជាជនរាប់សែននាក់បានស្លាប់ជាបន្តបន្ទាប់ដោយសារ ការធ្វើការហួសកម្លាំង និងគ្មានអាហារបរិភោគគ្រប់គ្រាន់។

-*វិសុទ្ធកម្ម៖* នៅពាក់កណ្តាលឆ្នាំ ១៩៧៦ សមាជិកសំខាន់ៗជាច្រើនរូបរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានធ្វើវិសុទ្ធកម្ម។ ចាប់ពីពេលនោះមក **ប៉ុល ពត** និងសហការីជឿថាការបះបោរប្រឆាំងនឹងថ្នាក់ដឹកនាំបក្សកាន់តែកើតមានច្រើនឡើងៗ។ ថ្នាក់ដឹកនាំទាំងនេះជឿថាសត្រូវរបស់ខ្លួនមាននៅគ្រប់ទីកន្លែង។ គណៈភូមិភាគ គណៈតំបន់ និងមេបញ្ជាការកងទ័ពជាច្រើនរូបត្រូវបានចាប់ខ្លួន និង សម្លាប់ចោល។ សភាពការណ៍កាន់តែមានសភាពធ្ងន់ធ្ងរទៅៗក្នុងឆ្នាំ១៩៧៧ នៅពេលដែល **ប៉ុល ពត** បញ្ជាឱ្យធ្វើការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា និងធ្វើវិសុទ្ធកម្មទៅលើប្រជាជនដែលរស់នៅភូមិភាគនេះស្ទើរគ្មានសល់។ នៅពេលវៀតណាមវាយចូលភូមិភាគនេះនៅចុងឆ្នាំ១៩៧៧ ជាជនសេសសល់ត្រូវបានចោទថាបានចូលដៃជាមួយវៀតណាម ហើយត្រូវបានមជ្ឈិមបក្សចាត់ទុកថាជា "មនុស្សក្បាលយួន ខ្លួនខ្មែរ"។ ហេតុដូច្នេះហើយ មជ្ឈិមបក្សបានបញ្ជូនកងទ័ពជាច្រើនមកវាយប្រហារភូមិភាគបូព៌ាដែលបានសម្លាប់ប្រជាជនរាប់ម៉ឺននាក់។ ប្រជាជនរាប់ពាន់នាក់បានរត់គេចខ្លួនទៅវៀតណាមដែលនៅទីនោះរដ្ឋាភិបាលវៀតណាមបានជួយបង្កើតកងកម្លាំងយោធាមួយ។

-*ការប៉ះទង្គិចជាមួយវៀតណាម៖* នេះគឺជាមូលហេតុធំបំផុតនៃការដួលរលំរបស់កម្ពុជា ប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមបង្កបញ្ហានៅតាមព្រំដែនជាបណ្តើរៗជាមួយវៀតណាម។ ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានផ្ទុះឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ គឺនៅពេលដែលខ្មែរក្រហមបានបាញ់ផ្លោងទៅលើទីរួមខេត្តចូវដុក ស្រុកហាទៀង និងខេត្តមួយចំនួនទៀតរបស់វៀតណាមដែលបណ្តាលឱ្យគ្រោះថ្នាក់ដល់ប្រជាជនស៊ីវិល និងកងទ័ពវៀតណាមជាច្រើននាក់ ដែលមិនបានត្រៀមខ្លួនជាមុន។ ប្រជាជនវៀតណាមរាប់ពាន់នាក់បានរត់ចូលទៅក្នុងផ្ទៃប្រទេស។ ក្នុងអំឡុងពេលតែពីរ-បីថ្ងៃនៃការវាយប្រហារប្រជាជនស៊ីវិលវៀតណាមប្រហែលមួយពាន់នាក់បានរងរបួស និងស្លាប់។

នៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានប្រើយន្តហោះ និងកាំភ្លើងធំបើកការវាយប្រហារទ្រង់ទ្រាយធំមួយមកលើកម្ពុជាប្រជាធិបតេយ្យ ដោយដណ្តើមកាន់កាប់បានតំបន់ចំពុះសេក ក្នុងខេត្តស្វាយរៀង។ កងទ័ពវៀតណាមបានវាយសម្រុកចូលជាងម្ភៃគីឡូម៉ែត្រមកក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ

ហើយកាន់កាប់បានទីរួមខេត្តស្វាយរៀង។ ឆ្លើយតបទៅវិញ កម្ពុជាប្រជាធិបតេយ្យបានកាត់ផ្ដាច់ចំណងការទូតជាមួយប្រទេសវៀតណាម ហើយបានបញ្ជាឱ្យអ្នកការទូតវៀតណាមទាំងអស់នៅទីក្រុងភ្នំពេញចាកចេញពីប្រទេសកម្ពុជា។ ខ្មែរក្រហមយល់ព្រមធ្វើការចរចា លុះត្រាតែ កងទ័ពវៀតណាមទាំងអស់ដកចេញពីទឹកដីកម្ពុជាប្រជាធិបតេយ្យជាមុនសិន។ មួយរយៈកាលក្រោយមកទៀត វៀតណាមបានដកទ័ពចេញពីប្រទេសកម្ពុជា ដោយកៀរទាំងអ្នកទោស និងប្រជាជនស៊ីវិលរាប់ពាន់នាក់ទៅជាមួយផង។ គ្មានការចរចាណាមួយត្រូវបានធ្វើឡើងទេ។

វៀតណាមបានចោទខ្មែរក្រហមថាបានធ្វើការវាយប្រហារទៅលើខេត្តទាំងប្រាំបីរបស់ខ្លួន ដែលស្ថិតនៅតាមបណ្ដោយព្រំដែនជាប់នឹងប្រទេសកម្ពុជា។ វៀតណាមបានជំរុញឱ្យមានការបង្កើតកម្លាំងបដិបក្ខមួយដើម្បីធ្វើការបះបោរប្រឆាំងនឹងខ្មែរក្រហម។ វៀតណាមក៏បានចាប់ផ្ដើមហ្វឹកហ្វឺនជនកម្ពុជាដែលរស់នៅក្នុងប្រទេសវៀតណាម ឱ្យចូលរួមក្នុងប្រតិបត្តិការយោធា និងបង្កើតកម្លាំងស្នូលសម្រាប់របបថ្មីមួយ។ ប្រទេសទាំងពីរបានប្រយុទ្ធគ្នាអស់ពេញមួយរយៈកាលនៃឆ្នាំ១៩៧៨។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយដែលផ្សាយជាភាសាខ្មែរបានអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់ក្រោកឈរឡើងប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ វៀតណាម បានជ្រើសរើសប្រជាជនខ្មែរមួយចំនួនដែលបានភៀសខ្លួនទៅវៀតណាមឱ្យចូលបម្រើក្នុងជួរកងទ័ព ដឹកនាំដោយវៀតណាម។ ភាគច្រើននៃជនជាតិខ្មែរទាំងនេះគឺជាកម្មាភិបាល កងទ័ព និងប្រជាជនមកពីភូមិភាគបូព៌ា។ មកត្រឹមពេលនេះ មួយផ្នែកនៃភូមិភាគបូព៌ាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ហើយមួយផ្នែកទៀតស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងកម្លាំងបះបោរដែលប្រឆាំងនឹងខ្មែរក្រហម។

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយបានផ្សព្វផ្សាយពីការបង្កើតនូវរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ រណសិរ្សនេះដឹកនាំដោយសមមិត្ត **ហេងសំរិន** ដែលបានភៀសខ្លួនទៅវៀតណាមនៅចុងឆ្នាំ១៩៧៨។

មេបញ្ជាការទ័ពវៀតណាម **វ៉ាន់ ទៀនឃុង** បានដឹកនាំធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាមកលើកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨។ ទ័ពរបស់ **វ៉ាន់ ទៀនឃុង** បានវាយកាន់កាប់ខេត្តក្រចេះក្នុងរយៈពេលប្រាំថ្ងៃ និងខេត្តកំពង់ចាមក្នុងរយៈពេលមួយសប្ដាហ៍។ បន្ទាប់មក នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមនិងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយដណ្ដើមបានរដ្ឋធានី

ភ្នំពេញ និង ស្ទើរតែផ្ទៃប្រទេសទាំងមូលក្នុងពេលបន្តបន្ទាប់ មកទៀត។ កងទ័ពទាំងពីរបានរៀបចំមហាសន្និបាតមួយ ដើម្បីបង្កើតក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ កម្ពុជាឱ្យធ្វើជារដ្ឋាភិបាលបណ្ដោះអាសន្ន ក្រោមការដឹកនាំរបស់សមមិត្ត **ហេង សំរិន**។

## ៨.២-កម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩

ដើមឆ្នាំ១៩៧៩ វៀតណាមបានជួយរៀបចំរបបថ្មីមួយនៅក្រុងភ្នំពេញដែលមានឈ្មោះថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា"។ របបនេះគ្រប់គ្រងប្រទេសកម្ពុជារហូតដល់វៀតណាមដកទ័ពចេញមួយទសវត្សរ៍ក្រោយមកទៀត គឺឆ្នាំ១៩៩០។ មេដឹកនាំ និងកងទ័ពកម្ពុជាប្រជាធិបតេយ្យបានរត់គៀសខ្លួនពីទីក្រុងភ្នំពេញទៅភាគពាយ័ព្យប្រទេស ដោយថ្មើរជើង ឡាន និងជិះរថភ្លើង។ ខ្មែរក្រហមបានកៀរប្រជាជនរាប់ម៉ឺននាក់ដោយបង្ខំឱ្យទៅជាមួយខ្លួន។ ក្នុងអំឡុងពេលនៃការជម្លៀសជាលើកទីពីរនេះ ប្រជាជនជាច្រើនបានស្លាប់ដោយសារ អត់អាហារ ជំងឺ និងរបួស។

ប្រជាជនជាច្រើនបានស្វះស្វែងរកផ្លូវត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ។ សម្ដេចព្រះ**នរោត្តម សីហនុ** និងព្រះញាតិវង្សានុវង្សត្រូវបានជម្លៀសតាមយន្តហោះទៅប្រទេសចិន។

ខ្មែរក្រហមបានរៀបចំអង្គការចាត់តាំងរបស់ខ្លួនឡើងវិញនៅតាមបណ្ដោយព្រំដែនថៃ ដោយមានជំនួយយោធាពីបរទេសរួមមានប្រទេសចិន និងប្រទេសថៃ។ រហូតមកដល់ឆ្នាំ១៩៩០ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុញ្ញាតឱ្យតំណាងរបស់កម្ពុជាប្រជាធិបតេយ្យបន្ត កាន់កាប់អាសនៈរបស់កម្ពុជា នៅអង្គការសហប្រជាជាតិ បើទោះបីជាមានការជំទាស់ពី សាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម្ព័ន្ធមិត្តសង្គមនិយមរបស់ខ្លួនមួយចំនួនក៏ដោយ។

ឆ្នាំ១៩៧៩ ខ្មែរក្រហមបានប្រកាសពីការបង្កើត "រណសិរ្សមហាសាមគ្គីជាតិ ស្នេហាជាតិ និងប្រជាធិបតេយ្យ"។ ប៉ុន្តែមិនបានទទួលការគាំទ្រពីប្រជាជនឡើយ។ នៅពេលជាមួយគ្នានោះដែរ ចលនាតស៊ូមិនមែនកុម្មុយនីស្តមួយ "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ" ត្រូវបានបង្កើតឡើងដឹកនាំដោយសម្ដេច **សឺន សាន** ដែលជាអតីតនាយករដ្ឋមន្ត្រីក្នុងសម័យសង្គមរាស្ត្រនិយម (១៩៥៩-១៩៧០)។

ក្រុមអ្នកតស៊ូរាជានិយមមួយដែលមានឈ្មោះថារណសិរ្សរួបរួមជាតិដើម្បីកម្ពុជាមួយឯករាជ្យ អព្យាក្រឹត សន្តិ និងសហប្រតិបត្តិ ហៅថា "ហ៊្វុនស៊ិនប៉ិច" (FUNCINPEC)"ក៏ត្រូវបានបង្កើតដែរ ក្នុងពេលបន្តបន្ទាប់គ្នានោះ ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្ដេចព្រះ **នរោត្តម សីហនុ**។ នៅឆ្នាំ១៩៨២ ក្រុមរាជានិយមហ្វុនស៊ិនប៉ិច ក្រុម

រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងក្រុមខ្មែរក្រហមបានរួបរួមគ្នាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគគី ដែលមានសម្តេចព្រះ **នរោត្តម សីហនុ** ជាប្រធាន **ខៀវ សំផន** ជាអនុប្រធាន និងសម្តេច **សឺន សាន** ជានាយករដ្ឋមន្ត្រី។ គោលបំណងរួមរបស់រដ្ឋាភិបាលនេះ គឺដើម្បីប្រមូលកម្លាំងធ្វើការតស៊ូរំដោះប្រទេសពីការជ្រៀតជ្រែករបស់ វៀតណាម។ រដ្ឋាភិបាលចម្រុះត្រីភាគីដែលមានក្រុមខ្មែរក្រហមជាក្រុមធំជាងគេនោះ បានកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ។

បន្ទាប់ពីការចរចាអស់រយៈពេលជាច្រើនឆ្នាំ ភាគីជម្លោះកម្ពុជាទាំងអស់បានយល់ព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ហើយ យល់ព្រមឱ្យមានការរៀបចំការបោះឆ្នោតជាតិមួយ ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា "អ៊ុនតាក់"។ ក្រុមខ្មែរក្រហមបានធ្វើពលិការមិនចូលរួមការបោះឆ្នោតជាតិដែលរៀបចំឡើងដោយអ៊ុនតាក់ ហើយបដិសេធមិនព្រមរំសាយកងទ័ពរបស់ខ្លួនឡើយ។ ក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ កងទ័ពខ្មែរក្រហមបានបន្តប្រយុទ្ធប្រឆាំងនឹងកងកម្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជានាយករដ្ឋមន្ត្រីទី១ និងសម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីទី២ អស់ជាច្រើនឆ្នាំបន្តទៀត។

នៅខែសីហា ឆ្នាំ១៩៩៦ **អៀង សារី** បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយនាំទាំងកងទ័ពមួយចំនួនមកជាមួយផង។ **សុន សេន** ត្រូវបានសម្លាប់នៅឆ្នាំ១៩៩៧។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនទៀតដូចជា **កែ ពក នួន ជា** និង **ខៀវ សំផន** បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៨។ បន្ទាប់ពី **ប៉ុល ពត** ទទួលមរណភាព នៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៩៨ **តាម៉ុក** ជាមេខ្មែរក្រហមតែម្នាក់គត់ដែលបដិសេធមិនព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៩៩។ ត្រឹមដំណាក់កាលនេះ មេដឹកនាំខ្មែរក្រហមដែលនៅរស់ទាំងអស់បានសារភាពចុះចាញ់ ឬត្រូវបានចាប់ខ្លួន ហើយចលនាខ្មែរក្រហមទាំងមូលបានដួលរលំជាស្ថាពរ។ ប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមតំបន់ត្រួតត្រារបស់ខ្មែរក្រហមទាំងអស់បានធ្វើមាតុភូមិនិវត្តន៍ និងរួបរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញ។

## ៩.ដំណើរប្រព្រឹត្តទៅនៃការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

នៅក្នុងឆ្នាំ២០០៦ តុលាការរួមគ្នាមួយរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋា

ភិបាលកម្ពុជា ត្រូវបានបង្កើតឡើងដោយដាក់ឈ្មោះថា «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ដើម្បីកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់ក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតលើ ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ តុលាការកូនកាត់ ដែលបានចាប់ដំណើរការតាំងពីខែកក្កដា ឆ្នាំ២០០៦ និងបានបញ្ចប់នៅក្នុងខែសីហា ឆ្នាំ ២០២២ ជាមួយការចំណាយថវិកាចំនួន៣៣៧លានដុល្លារ បានកាត់ទោសលើសំណុំរឿងធំៗពាក់ព័ន្ធនឹងមេខ្លោងសំខាន់ៗដែលទទួលខុសត្រូវក្នុងរបបខ្មែរក្រហមដែលបានកាប់សម្លាប់មនុស្សពីអតីតកាល។

### ៩.១-សំណុំរឿង ០០១

**កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** (អតីតប្រធានមន្ទីរស-២១ ) ត្រូវបានអង្គជំនុំជម្រះសាលាដំបូងផ្តន្ទាទោសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារ បំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ គាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ហើយត្រូវបានកាត់បន្ថយមកត្រឹមរយៈពេល៣០ឆ្នាំ ជាការទូទាត់ សំណងទៅនឹងការឃុំខ្លួនគាត់ដោយមិនប្រក្រតីកន្លងមកដោយតុលាការយោធាកម្ពុជា។ ជនជាប់ចោទ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមទៅកាន់អង្គជំនុំជម្រះតុលាការកំពូល។

ក្រោយមក អង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីកាកាត់ទោសគាត់ឱ្យជាប់ ពន្ធនាគារ អស់មួយជីវិត។

### ៩.២-សំណុំរឿង ០០២

**នួន ជា** (អតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងអនុលេខាបក្សកុម្មុយនីស្តកម្ពុជា) ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនានៅក្រោមច្បាប់កម្ពុជា។

**អៀង សារី** (អតីតរដ្ឋមន្ត្រីការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនានៅក្រោមច្បាប់កម្ពុជា។

**អៀង ធីរិទ្ធ** (អតីតរដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាង

ធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា នៅក្រោមច្បាប់កម្ពុជា។

**ខៀវ សំផន** (អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញា ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា នៅក្រោមច្បាប់កម្ពុជា។

ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ មានមនុស្សស្លាប់ជាង ៣លាននាក់ ព្រមទាំងបានបន្សល់ទុកនូវជនពិការ កុមារកំព្រា និងស្ត្រីមេម៉ាយ រាប់សែននាក់។ របបវាលពិឃាតនេះ ត្រូវបានផ្តួលរំលំក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានរំដោះប្រទេសនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ទោះបីអតីតកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ បានកន្លងផុតទៅអស់រយៈពេលជាង៤០ឆ្នាំទៅហើយក្តី ប៉ុន្តែ ស្នាមរបួសផ្លូវចិត្តនៅតែដិតដាមមិនអាចបំភ្លេចបាន៕

## ឯកសារយោង

១-ជួន ណាតះ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

២-ឌី ខាំបូលី «**ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩**» មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៧

៣-ណុន សុខា «**ឥទ្ធិពលមនោគមវិជ្ជានៃអក្សរសិល្ប៍កម្ពុជាប្រជាធិបតេយ្យ**» និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ ឆ្នាំ២០១៥

៤-ម៉ៅ អាយុទ្ធ «**សំឡេងសាដៀវ**» រង្វាន់ជ័យលាភីតែងនិពន្ធក្របខ័ណ្ឌអាស៊ាន ឆ្នាំ២០០១

៥-សារព័ត៌មាន FRESH NEWS (https://freshnewsasia.com/index.php/en/localnews/384359-2025-04-17-02-40-13.html)